# អរិយធម៌មេសូប៉ូតាមី

តំបន់ Mesopotamia ដែលអ្នកស្រាវជ្រាវចាត់ទុកថា ជាអរិយធម៌ចាស់ជាងគេក្នុងចំណោមអរិយធម៌ដំបូងៗក្នុងប្រវត្តិពិភពលោកដែលបច្ចុប្បន្នស្ថិតនៅរវាងប្រទេស ស៊ីរី គូវេត និង អ៊ីរ៉ាក់ (រូបលេខ១)។

ពាក្យ Mesopotamia គឺមានន័យថា "ចន្លោះទន្លេ"[១]ដោយអរិយធម៌នេះមានការរីកចម្រើនអរិយធម៌ខ្លួននៅតំបន់ចន្លោះទន្លេពីរ គឺ ទន្លេ Tigris និង ទន្លេ Euphrates។ ការជ្រើសរើសតាំងទីនៅតាមតំបន់ទន្លេនេះ គឺស្របទៅតាមវិស័យកសិកម្ម នេសាទ និងការចិញ្ចឹមសត្វដែលពឹងផ្អែកទៅលើប្រភពទឹក ។

នៅក្នុងអរិយធម៌នេះមានអាណាចក្រធំ៥ធំៗគឺ Sumer, Akkad Babylon Assyrian និង Persian (រូបលេខ២)។ អាណាចក្រ Akkad ត្រូវបានបែងចែកចេញពីរផ្សេងទៀត គឺអាណាចក្រ Assyrian និង Babylon។[២] ទីក្រុងដំបូងនៃអរិយធម៌នេះ គឺមានឈ្មោះថា Ur ដែលមានអាយុកាលប្រមាណ៣៨០០ឆ្នាំ មុនគ.ស. ដោយមានការរៀបចំហេដ្ឋារចនាសម្ព័ន្ធដូចជាមានកំពែងពីដីផ្ទះប្រជាជនកសាងតាមអក្ស័បណ្ដោយថ្ងៃ ទទឹងថ្ងៃ ហើយប្រាសាទដែលល្បីល្បាញជាងគេ គឺមានឈ្មោះថា Ziggurat សម្រាប់ឧទ្ទិសដល់អធិទេពមួយដែលមានឈ្មោះថា Anu ( Sky god) (រូបលេខ៣)។[៣]ប្រាសាទ Ziggurat គឺសម្រាប់ឧទ្ទិសដល់អធិទេពផ្សេងៗដែលមនុស្សក្នុងអរិយធម៌នេះគោរព។

ក្រុមមនុស្សនៅក្នុងអរិយធម៌នេះ បានបង្កើតជាទម្រង់អក្សរដែលហៅថា Cuneiform[៤] ដែលមនុស្សក្នុងអរិយធម៌នេះ បានបង្កើតឡើងប្រមាណ៣២០០ឆ្នាំមុនគ.ស(រូបលេខ៤)។[៥]

---

[១] Jean Jacques, 2002, p.7.

[២] *ibid*

[៣] Leo Oppenheim, 1977, p.9.

[៤] អក្សរដែលមានទម្រង់ជារូបគំនូរ ។

[៥] Leo Oppenheim, 1977, p.23.

អត្ថបទដោយ៖ អេង តុលា

ការបង្កើតអក្សរ គឺត្រូវបានគេចាត់ទុកថាជាដែនកំណត់នៃសម័យកាលបុរេប្រវត្តិ និងប្រវត្តិសាស្ត្រ ប៉ុន្តែការកំណត់ដែនបុរេប្រវត្តិសាស្ត្រ គឺមិនត្រូវបានកំណត់ដូចគ្នាទូទៅពិភពលោកនោះទេ។ ក្នុងចំណោមអាណាចក្រធំទាំងបីនោះ អាណាចក្រ Babylon ដែលគេស្គាល់ច្រើនជាងគេ ហើយអាណាចក្រនេះ មានរាជធានីនៅក្បែរទីក្រុងបាដាត នៃប្រទេស អ៊ីរ៉ាក់បច្ចុប្បន្នហើយអាណាចក្រ Babylonសម័យបុរាណមានមហាក្សត្រមួយអង្គគឺព្រះនាម Hammurabi ដែលមានឈ្មោះល្បីល្បាញក្នុងការបង្កើតច្បាប់ក្រមដែលអ្នកស្រាវជ្រាវហៅថាច្បាប់ Hammurabi (រូបលេខ៥) ដែលបានរកឃើញនៅតំបន់ Susa ហើយសព្វថ្ងៃរក្សាទុកនៅសារមន្ទីរLouvre នៃប្រទេសបារាំង។[៦] ប៉ុន្តែភាពជោគជ័យរបស់អរិយធម៌មេសូប៉ូតាមីក៏បានបញ្ចប់ ដោយសារការដួលរលំអាណាចក្រ Babylone ពីការឈ្លានពានទឹកដី នៅឆ្នាំ ៥៣៩មុនគ.ស ពីស្តេចនៃចក្រភពពែក បានធ្វើការដណ្តើមយក Babylone និងពង្រីកអំណាចរបស់ខ្លួន ក្នុងការកាន់កាប់តំបន់នៃអរិយធម៌មេសូប៉ូតាមីទាំងមូល ហើយបានកាន់កាប់តំបន់ទាំងនោះអស់ច្រើនសតវត្ស។[៧]

តាមរយៈការស្រាវជ្រាវបុរាណវិទ្យា ចាប់តាំងពីទសវត្សទី៨០ ពោល គឺចាប់ពីឆ្នាំ ១៨៤២មក អ្នកបុរាណវិទូបានកំណាយរកឃើញកស្តុតាងជាច្រើននៃតំបន់អរិយធម៌នេះ ដែលភស្តុតាងទាំងនោះមានដូចជា សិលាចារឹក , កុលាលភាជន៍ , បដិមា និងការរកឃើញ របនាសម្ព័ន្ធក្រុងបុរាណដែរ ដែលភស្តុងចាស់ជាងគេមានអាយុកាលប្រមាណ ៣២០០ឆ្នាំ មុនគ.ស. និងមានវត្ថុសិល្បៈជាច្រើនទៀតបានតម្កល់ទុកនៅសារមន្ទីរបរទេស ជាពិសេសនៅសារមន្ទីល្លូវនៅទីក្រុងប៉ារីសប្រទេសបារាំង។ សំណង់នៅតំបន់មេសូប៉ូតាមីភាគច្រើនកសាងពីដីឥដ្ឋដែលមិនអាចនៅរហូតដល់បច្ចុប្បន្ន។

---

[៦] Leo Oppenheim, 1977, p.143.

[៧] *ibid*, p.400.

អត្ថបទដោយ៖ អេង តុលា




រូបលេខ១៖ ផែនទីនៃអរិយធម៌មេសូប៉ូតាមីបុរាណ

ប្រភព៖ World history.com



រូបលេខ២៖ ផែនទីនៃទីក្រុងKhorsabad

ប្រភព៖ Archeologie.culture.fr

អត្ថបទដោយ៖ អេង តុលា



រូបលេខ២៣៖ ប្រាសាទ Ziggaurat of Ur

ប្រភព៖ https://www.britannica.com/art/Mesopotamian-art



រូបលេខ២៤៖ អទិទេព Anu ក្នុងសិល្បៈមេសូប៉ូតាមី

ប្រភព៖ World history.com

អត្ថបទដោយ៖ អេង តុលា

អត្ថបទដោយ៖ អេង៍ តុលា



រូបលេខ៩៖ សិលាចារឹកដែលបង្ហាញពីរូបស្តេច និងទេព ហើយជាសិលាចារឹកអំពីច្បាប់របស់ស្តេច Hammurabi

អត្ថបទដោយ៖ អេង តុលា



រូបលេខ៦៖ អក្សរCuniform

ប្រភព៖ World history.com



រូបលេខ៧៖ ភាជន៍ដែលគំនូរវ័ណ្ណ
ជុំវិញ ក្នុងសិល្បៈមេសូប៉ូតាមី

ប្រភព៖ World history.com

# ឯកសារយោង

Jean Jacques Glassner

2002. "La Mésopotamie''

Jean Louis Hout

2004. "Une archéologie des peuples du proche Orient Tome I et Tome II''

# ឯកសារយោងអ៊ីនធើណែត

https://www.geo.fr/histoire/mesopotamie-les-grandes-periodes-de-son-histoire-196460
https://www.history.com/topics/ancient-middle-east/mesopotamia

Youtube:

- The Ancient City of Babylon: History of the Babylonian Empire by World History Encylopedia
- Ancient Mesopotamia 101 by National Geographic

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ អេង តុលា